# ប្រស្នាធម៌

ព្រះញាណបវរវិជ្ជា អែម ចាងហ្វាងសាលាបាឡីជាន់ខ្ពស់នៅក្រុងភ្នំពេញ

## រៀបរៀង

— ៦ —

## ៤– សក្កបញ្ហា ប្រស្នាព្រះឥន្ទ្រសួរព្រះសម្មាសម្ពុទ្ធ

រឿងនេះមានក្នុងគម្ពីរព្រះធម្មបទបឋមភាគ ខ្សែ ១៦ សម្តែងសេចក្តីថា ព្រះទសពលញាណជាសាស្តាកាលព្រះអង្គគង់នៅក្នុងវិហារព្រះជេតពនទៀបក្រុងនគរសាវត្ថី ទ្រង់ប្រារព្ធបំពោះនឹងសក្កទេវរាជហើយសម្តែងនូវធម្មទេសនានេះមានបទថា សព្វទានំ ធម្មទានំ ជយតិ ជាដើម ។

សម័យមួយទេវតាទាំងឡាយ ប្រជុំគ្នាព្រមក្នុងស្ថានទេវលោកឈ្មោះតាវតឹំសភព ហើយញាំងប្រស្នាទាំងឡាយ៤បំពួកឲ្យកើតឡើងព្រមថាដូច្នេះ ១– កតរំ ទានំ នុ ខោ ទានេសុ ជំនុំទានទាំងឡាយ ទានដូចម្តេចហ្ន៎ គឺអ្នកប្រាជ្ញទាំងឡាយពោលថា

ជាធំប្រសើរដោយវិសេសជាងទានទាំងពួង. ២– កតរោរ សោរសេសុ ជិនុំរសទាំងឡាយ រសដូចម្ដេចហ្ន៎ គឺអ្នកប្រាជ្ញទាំងឡាយពោលថាជាធំប្រសើរដោយវិសេសជាងរសទាំងពួង. ៣– កតរាតិ រតីសុជេដ្ឋកា ជិនុំសេចក្ដីត្រេកអរទាំងឡាយ សេចក្ដីត្រេកអរដូចម្ដេចហ្ន៎ គឺអ្នកប្រាជ្ញទាំងឡាយពោលថាជាធំប្រសើរដោយវិសេសជាងសេចក្ដីត្រេកអរទាំងពួង. ៤– តណ្ហក្ខយោកស្មាជេដ្ឋកោតិវុច្ចតិ កិរិយាអស់ទៅនៃតណ្ហា គឺអ្នកប្រាជ្ញទាំងឡាយពោលថាជាធំដោយវិសេសព្រោះហេតុអ្វី ។ សូម្បីតែទេវតាមួយក៏ពុំអាចដើម្បីវិនិច្ឆ័យនូវប្រស្នាទាំងឡាយនោះឲ្យដាច់ស្រេចបាន ទេវតាមួយសួរទៅទេវតាមួយទៀត ទេវតានោះសួរតទៅទេវតាដទៃទៀត ព្រោះហេតុដូច្នោះទេវតាទាំងឡាយនោះកាលសួរគ្នានឹងគ្នាទៅមកយ៉ាងនេះពុំបេះដាច់ស្រេច ត្រេបទៅក្នុងចក្កវាឡមួយម៉ឺន លោកធាតុកន្លងទៅបាន ១២ ឆ្នាំគត់ ។

ទេវតាទាំងឡាយទាំងមួយម៉ឺនលោកធាតុ បង្កើតជាកោលាហលជ្រួលជ្រើមគឺកកងបបួលគ្នារំពឹងគិតពិចារណារាវរកនូវសេចក្ដីអធិប្បាយនៃប្រស្នាទាំង ៤ ចំពួកនោះ ពុំបានឃើញនូវ

សេចក្តីអធិប្បាយប្រស្នានោះសោះដោយកាលកន្លងទៅជាយូរ ប្រមាណ ១២ ឆ្នាំ ហើយប្រជុំគ្នាចូលកាន់សំណាក់ស្តេចធំទាំង ៤ នាកាលពាក្យពោលថាម្នាលអ្នកទាំងឡាយ កិរិយាប្រជុំនៃទេវតាដ៏ច្រើនយ៉ាងនេះតើប្រយោជន៍អ្វី គឺស្តេចធំទាំងឡាយ ៤ នោះពោលហើយ ៗ ក្រាបទូលថា បពិត្រមហារាជទាំងឡាយ យើងទាំងឡាយបានញាំងប្រស្នាទាំងឡាយ ៤ បំពូកឲ្យតាំងឡើងព្រម ហើយពុំអាចវិនិច្ឆ័យឲ្យដាច់ស្រេចបាន ៗ ជាបបួលគ្នាចូលមកកាន់សំណាក់ព្រះអង្គទាំងឡាយ ។

ស្តេចធំទាំង ៤ បានស្តាប់ហើយ ពោលថា តាតា ម្នាលអ្នកទាំងឡាយ ប្រស្នាទាំង ៤ បំពូកនោះដូចម្តេចខ្លះ ។

ទេវតាទាំងឡាយពោលថា បពិត្រមហារាជទាំងឡាយ ជំនុំទាននឹងរស នឹងសេចក្តីត្រេកអរទាំងឡាយ ទាននឹងរស នឹងសេចក្តីត្រេកអរដូចម្តេចហ្ន៎ជាធំប្រសើរដោយវិសេស កិរិយាអស់ទៅនៃតណ្ហាឈ្មោះថាធំប្រសើរដោយវិសេសព្រោះហេតុអ្វី យើងទាំងឡាយពុំអាចដើម្បីជំរះនូវប្រស្នាទាំងឡាយនេះបាន ៗ

ជាប្ចូលមកកាន់សំណាក់ព្រះអង្គសូមវិនិច្ឆ័យសេចក្ដីនេះដល់យើងទាំងឡាយ ។

ស្ដេចធំទាំង ៤ នោះបានស្ដាប់ហើយពោលថា ម្នាលអ្នកទាំងឡាយ យើងទាំងឡាយក៏ពុំបានដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នាទាំងឡាយនោះដែរ តែថាស្ដេចនៃយើងទាំងឡាយព្រះអង្គរំពឹងគិតនូវហេតុទាំងឡាយគឺជន ១ ពាន់នាក់គិតហើយអាចជ្រាបបានដោយកាលមួយរំពេច ស្ដេចនៃយើងទាំងឡាយនោះ ព្រះអង្គប្រសើរដោយវិសេសជាងយើងទាំងឡាយ ដោយប្រាជ្ញាផង ដោយបុណ្យផង ព្រោះហេតុដូច្នោះប្ចូរអ្នកទាំងឡាយប្ចូលមក យើងទាំងឡាយនឹងទៅកាន់សំណាក់នៃទេវរាជនោះ ពោលដូច្នេះហើយក៏កាន់យកពពួកទេវតានោះប្ចូលទៅកាន់សំណាក់នៃសក្កទេវរាជ គឺទេវរាជនោះបានសួរហើយក្រាបទូលសេចក្ដីនោះសព្វគ្រប់ប្រការ ។

ឯសម្ដេចព្រះបមទិព្យឥន្ទ្រាធិរាជ ទ្រង់បានស្ដាប់ហើយពោលថាម្នាលអ្នកទាំងឡាយ បុគ្គលដទៃពុំអាចដើម្បីដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នាទាំងឡាយនេះឡើយ ប្រស្នាទាំង

ឡាយនេះជាវិស័យនៃព្រះសម្មាសម្ពុទ្ធពិត ព្រះអង្គពោលដូច្នេះ ហើយក៏សួរថាព្រះសាស្តាជាម្ចាស់ឥឡូវនេះព្រះអង្គគង់ក្នុងទីឯណា ទេវតាទាំងឡាយទូលថា ព្រះសម្មាសម្ពុទ្ធព្រះអង្គគង់នៅក្នុងវិហារឈ្មោះព្រះជេតពន ព្រះអង្គបានស្តាប់ហើយពោលថា បើដូច្នោះអ្នកទាំងឡាយចូរមក យើងទាំងឡាយនឹងទៅកាន់សម្នាក់នៃព្រះដ៏មានព្រះភាគនោះ ។ ព្រះឥន្ទ្រាធិរាជព្រមទាំងពួកទេវតាក៏ហោះចុះមកកាន់ស្ថានមនុស្សលោកមួយរំពេចដោយរិទ្ធិ ក្នុងវេលាពាក់កណ្តាលរាត្រីហើយញាំងវិហារព្រះជេតពនទាំងអស់ឲ្យភ្លឺស្វាងរុងរឿងស្រេចហើយចូលទៅកាន់សម្នាក់ព្រះសាស្តាជាម្ចាស់ ថ្វាយបង្គំហើយស្ថិតនៅក្នុងទីដ៏សមគួរមួយ ។

ព្រះបរមគ្រូវសាស្តាចារ្យ ទ្រង់សួរថាបពិត្រមហារាជព្រះអង្គយាងមកដោយពពួកទេវតាមានប្រមាណច្រើនយ៉ាងនេះតើមានប្រយោជន៍អ្វី ។

សម្តេចព្រះអម្រិន្ទ្រាធិរាជ ទូលថាបពិត្រព្រះដ៏មានបុណ្យដ៏ចំរើន ដ្បិតមានប្រស្នាទាំងឡាយ ៤ បំពួក គឺពួកទេវតាទាំងពួងបណ្តាលឲ្យកើតឡើងក្នុងទេវលោក ឈ្មោះថាបុគ្គល

ឯណាមួយដ៏អាចដើម្បីដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នាទាំង-ឡាយនេះពុំមានឡើយ សូមព្រះអង្គទ្រង់សម្ដែងនូវសេចក្ដីអ-ធិប្បាយនៃប្រស្នាទាំងឡាយនេះ ដល់យើងទាំងឡាយ ។

ព្រះបរមបពិត្រវិជិតមារជាម្ចាស់ ព្រះអង្គមានព្រះពុទ្ធដីកាថា សាធុមហារាជ បពិត្រមហារាជប្រិតៃហើយ សព្វញ្ញុតញ្ញាណដែលព្រះតថាគតបានកសាងសន្សំញុំាងបារមីទាំងឡាយ ៣០ គត់ឲ្យពេញបរិបូណ៌បានលះបង់នូវមហាបរិច្ចាគទាំងឡាយ ៥ ហើយបានត្រាស់ដឹងហើយ មិនមានប្រយោជន៍អ្វីដទៃទេ ប្រយោជន៍តែនឹងកាត់បង់នូវសេចក្ដីសង្ស័យនៃបុគ្គលទាំងឡាយប្រាកដស្មើដោយព្រះអង្គ បើដូច្នេះព្រះអង្គចូរស្ដាប់នូវប្រស្នាទាំងឡាយដែលព្រះអង្គបានសួរហើយ បពិត្រមហារាជ ធម្មទានជាធំប្រសើរជាងទានទាំងពួង រសធម៌ ជាធំប្រសើរជាងរសទាំងពួង សេចក្ដីត្រេកអរក្នុងធម៌ជាធំប្រសើរជាងសេចក្ដីត្រេកអរទាំងពួង បំណែកខាងកិរិយាអស់ទៅនៃតណ្ហា ជាធំប្រសើរដោយវិសេសព្រោះញុំាងសត្វទាំងឡាយឲ្យដល់នូវព្រះ

ឲ្យធ្វើនូវសែនទាំងឡាយមិនតែមួយ នៃវិហារទាំងឡាយប្រាកដ ស្មើដោយមហាវិហារ នៃប្រាសាទទាំងឡាយប្រាកដស្មើដោយ លោហប្រាសាទ ហើយឲ្យហើយផង. ជាងបរិច្ចាគគឺជនទាំង ឡាយមានសេដ្ឋីឈ្មោះអនាថបិណ្ឌិកជាដើមហើយផង ។

មានពាក្យបុច្ឆាសួរថាធម្មទានមានផលានិសង្សខ្ពង់ខ្ពស់ដ៏ ប្រសើរដោយវិសេសយ៉ាងនេះតើព្រោះហេតុអ្វី ។

ពាក្យវិសជ្ជនាឆ្លើយថាមហាជនទាំងឡាយ កាលដែល បានធ្វើនូវបុណ្យទាំងឡាយមានសភាពដូច្នេះ ព្រោះតែបាន ស្ដាប់បានដឹងច្បាស់ហើយទើបធ្វើ បើពុំបានស្ដាប់ពុំបានដឹង ហើយក៏ពុំបានធ្វើនូវបុណ្យមានសភាពដូច្នេះដែរ ។

ថាបើសត្វទាំងឡាយនេះមិនគប្បីស្ដាប់នូវធម៌ទេសនាទេ ក៏មិនគប្បីឲ្យនូវទានសូម្បីតែបបរមួយបោយឬបាយមួយវែកក៏ពុំ បានឲ្យដោយពិត ធម្មទានជាទានមានផលានិសង្សធំដ៏ប្រសើរ ដោយវិសេស ជាងទានទាំងពួងដោយហេតុមានប្រមាណ ប៉ុណ្ណោះ ។

ម្យ៉ាងវិញទៀតវៀរលែងតែព្រះសម្មាសម្ពុទ្ធនឹងព្រះបច្ចេក-

អរហត្តដោយពិត ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងដូច្នេះហើយ ពោលជាបទព្រះគាថាដូច្នេះថា ។

សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ
សព្វរតឹ ធម្មរតិ ជិនាតិ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ

ប្រែថា កិរិយាឲ្យនូវធម៌ ឈ្នះនូវទានទាំងពួង រសធម៌ ឈ្នះនូវរសទាំងពួង, សេចក្ដីត្រេកអរក្នុងធម៌ ឈ្នះសេចក្ដីត្រេកអរទាំងពួង កិរិយាអស់ទៅនៃតណ្ហា ឈ្នះនូវកងទុក្ខទាំងអស់ ។ សេចក្ដីនេះប្រែត្រង់តាមបាឡីយ ពីនេះនឹងអធិប្បាយតាមបទអដ្ឋកថាឲ្យពិស្ដារតៈទៅទៀត ។ ប្រស្នាទី ១ សេចក្ដីពិស្ដារថា បើបុគ្គលគប្បីឲ្យនូវត្រៃចីវរទាំងឡាយ ដ៏មានសម្ប៉ត់ល្អប្រាកដស្មើដោយបណ្ដូលចេក ដល់ព្រះសម្មាសម្ពុទ្ធនឹងព្រះបច្ចេកពុទ្ធនឹងព្រះខីណាស្រពទាំងឡាយ គង់នៅក្នុងកណ្ដាប់បក្កវាឡមួយតាំងពីស្ថានមនុស្សដ៏រាបដល់ព្រហ្មលោកនាយ ធ្វើពុំឲ្យមានចន្លោះឡើយ កិរិយាអនុមោទនាពិត គឺធម្មកថិកបានធ្វើដោយគាថាប្រកបដោយបាទ ៤ ក្នុងទីប្រជុំធំនោះ ជាគុណជាតិធំប្រសើរដោយវិសេសជាងឲ្យនូវអាមិស្សទាននោះដោយ

ពិត ផលានិសង្សអាមិស្សទាននោះ សូម្បីតែមួយចំណិតមួយ
ផ្ទឹងក៏ពុំបានឡើយ កិរិយាសម្តែងនូវធម៌ក្តី កិរិយាបង្ហាត់
បង្ហាញនូវធម៌ក្តី ជាធម្មទានមានផលានិសង្សដ៏ធំប្រសើរយ៉ាង
នេះ ។ ម្យ៉ាងវិញទៀតឯធម្មសវនគឺកិរិយាស្តាប់នូវធម៌ គឺ
បុគ្គលឯណាបានធ្វើហើយ មហានិសំសោ អានិសង្សច្រើន
ដ៏ធំទូលាយនឹងកើតមានប្រាកដ ដល់បុគ្គលនោះដោយពិត ។

ដ៏ហោចទៅសូម្បីតែធម្មទានដែលអ្នកបើកឲ្យប្រព្រឹត្តទៅ
ដោយអំណាចនៃអនុមោទនា ដោយគាថាប្រកបដោយបាទ ៤
បុណ្ណោះគង់ជាធម្មទានដ៏ធំប្រសើរដោយវិសេស ជាងបិណ្ឌបាត
ទានគឺបរិសទ្យមានសភាពដូច្នោះ ញុំាងបាត្រទាំងឡាយឲ្យ
ពេញដោយបិណ្ឌបាតដ៏ប្រសើរហើយឲ្យហើយ ដល់ព្រះបច្ចេក-
ពុទ្ធព្រះខីណាស្រពទាំងឡាយនោះផង ជាងភេសជ្ជទានគឺបរិ-
សទ្យមានសភាពដូច្នោះ ញុំាងបាត្រទាំងឡាយឲ្យពេញដោយ
វត្ថុទាំងឡាយមានសប្បិនឹងប្រេងជាដើម ហើយឲ្យហើយដល់
ព្រះពុទ្ធព្រះបច្ចេកពុទ្ធព្រះខីណាស្រពទាំងឡាយនោះផង ជាង
សេនាសនទានគឺបរិសទ្យមានសភាពដូច្នោះ ញុំាងគ្នានឹងគ្នា

ឲ្យធ្វើនូវសែនទាំងឡាយមិនតែមួយ នៃវិហារទាំងឡាយប្រាកដស្មើដោយមហាវិហារ នៃប្រាសាទទាំងឡាយប្រាកដស្មើះដោយលោហប្រាសាទ ហើយឲ្យះហើយផង. ជាងបរិច្ចាគគឺធនទាំងឡាយមានសេដ្ឋីឈ្មោះអនាថបិណ្ឌិកជាដើមហើយផង ។

មានពាក្យបុច្ឆាសួរថាធម្មទានមានផលានិសង្សខ្ពង់ខ្ពស់ដ៏ប្រសើរដោយវិសេសយ៉ាងនេះតើព្រោះហេតុអ្វី ។

ពាក្យវិសជ្ជនាឆ្លើយថាមហាជនទាំងឡាយ កាលដែលបានធ្វើនូវបុណ្យទាំងឡាយមានសភាពដូច្នេះ ព្រោះតែបានស្តាប់បានដឹងច្បាស់ហើយទើបធ្វើ បើពុំបានស្តាប់ពុំបានដឹងហើយក៏ពុំបានធ្វើនូវបុណ្យមានសភាពដូច្នេះដែរ ។

ថាបើសត្វទាំងឡាយនេះមិនគប្បីស្តាប់នូវធម៌ទេសនាទេក៏មិនគប្បីឲ្យនូវទានសូម្បីតែបបរមួយបោយឬបាយមួយវែកក៏ពុំបានឲ្យះដោយពិត ធម្មទានជាទានមានផលានិសង្សធំដ៏ប្រះសើរដោយវិសេស ជាងទានទាំងពួងដោយហេតុមានប្រមាណប៉ុណ្ណោះ ។

ម្យ៉ាងវិញទៀតវៀះលែងតែព្រះសម្មាសម្ពុទ្ធនឹងព្រះបច្ចេក-

ពុទ្ធទាំងឡាយចេញ ឯអគ្គសាវកទាំងឡាយមានព្រះថេរឈ្មោះ សារីបុត្តជាដើមប្រកបហើយដោយប្រាជ្ញា នាកាលទឹកភ្លៀងកាលធ្លាក់ចុះអស់កប្បទាំងអស់ ដ៏អាចហើយដើម្បីរាប់នូវដំណក់នៃទឹកភ្លៀងទាំងឡាយនោះបានដោយមិនឲ្យមានសល់ តែគង់ពុំអាចដើម្បីត្រាស់ដឹងនូវផលទាំងឡាយ មានសោតាបត្តិផលជាដើមដោយធម្មតាខ្លួនឯងបាន ដរាបតែបានស្តាប់នូវធម៌គឺព្រះថេរទាំងឡាយមានអស្សជិត្ថេរជាដើម ទើបធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលបាន លុះបានស្តាប់ធម្មទេសនានៃព្រះបរមគ្រូជាម្ចាស់ទៀត ទើបធ្វើឲ្យជាក់ច្បាស់នូវបារមីញាណបាន ។ ឯធម្មទាននេះជាទានមានផលធំដោយវិសេសដោយហេតុមានប្រមាណប៉ុណ្ណោះ ដោយពិត ព្រោះហេតុដូច្នោះបានជាសម្តេចព្រះមុនិន្ទជិនស្រីជាម្ចាស់ ទ្រង់សំដែងថា សព្វទានំ ធម្មទានំជិនាតិ ប្រែថា ធម្មទានអាចឈ្នះនូវទានទាំងអស់ក្នុងលោក គ្មានទានអ្វីផ្ទឹមបាន ។ ប្រស្នាទីពីរ អធិប្បាយថារសទាំងឡាយទាំងពួងមានរសនៃដើមជាដើមក្តី រសនៃសុធាភោជនរបស់ទេវតាទាំងឡាយដោយចំណែកជាឧក្រិដ្ឋក្តី រសទាំងអស់នោះឈ្មោះ

ជារសដែរ តែជាជារសគ្រាន់តែជាបច្ច័យនៃកិរិយាញ៉ាំងសត្វទាំងឡាយឲ្យធ្លាក់ចុះក្នុងសំសារវដ្ដហើយសោយនូវទុក្ខវេទនារឿយ ៗ ប៉ុណ្ណោះដោយពិត ។

បំណែកខាងឯរសធម៌ឯណាគឺបណ្ឌិតពោលថាបក្ខិយធម៌ទាំង ៣៧ ដ៏ប្រសើរក្ដី គឺបណ្ឌិតពោលថាលោកុត្តរធម៌ទាំង ៩ ក្ដីរសធម៌យ៉ាងនេះ ទើបបានឈ្មោះថាជារសធម៌ធំដ៏ប្រសើរដោយវិសេសជាងរសទាំងឡាយទាំងពួងដោយពិត ព្រោះហេតុដូច្នោះបានជាសម្ដេចព្រះលោកុត្តមាចារ្យជាម្ចាស់ ទ្រង់សម្ដែងថា សព្វរសំ ធម្មរសោ ជិនាតិ ប្រែថារសធម៌អាចឈ្នះនូវរសទាំងអស់ក្នុងលោក គ្មានរសអ្វីផ្ទឹមបាន ។

ប្រស្នាទីបី អធិប្បាយថាសេចក្ដីត្រេកអរឯណា មានប្រភេទច្រើនមិនតែមួយ មានសេចក្ដីត្រេកអរក្នុងកូនប្រុសនឹងកូនស្រីនឹងទ្រព្យនឹងត្រេកអរក្នុងល្បែងលេងស្រីនឹងល្បែងរាំនឹងច្រៀងនឹងប្រគំជាដើម សេចក្ដីត្រេកអរទាំងអស់នោះឈ្មោះថាត្រេកអរដែរ តែថាជាសេចក្ដីត្រេកអរគ្រាន់តែជាបច្ច័យនៃកិរិយា

ញាំងសត្វទាំងឡាយ ឲ្យធ្លាក់ចុះក្នុងសំសារវដ្ដហើយសោយនូវទុក្ខវេទនារឿយ ៗ បុណ្ណោះដោយពិត ។

បីតិគឺចេតនាដែលត្រេកអរមានកំឡាំងឯណា កាលកើតឡើងខាងក្នុងនៃសន្ដាន នៃបុគ្គលកាលសម្ដែងនូវធម៌ក្ដី កាលស្ដាប់នូវធម៌ក្ដី កាលបង្ហាត់បង្ហាញនូវធម៌ក្ដី បីតិគឺចេតនាដែលត្រេកអរមានកំឡាំងនោះញាំងភាវនៃខ្លួនជាបុគ្គលមានចិត្តនឹងរាងកាយឲ្យរីករាយឲ្យកើតឡើងផង ញាំងទឹកភ្នែកទាំងឡាយឲ្យប្រព្រឹត្តទៅផង ញាំងសេចក្ដីព្រឺព្រួចនៃរោមឲ្យកើតឡើងផង បីតិនោះទើបឈ្មោះថាធ្វើឲ្យផុតចាកសំសារវដ្ដ មានព្រះអរហត្តជាទីបំផុតមានដោយពិត ។

សេចក្ដីត្រេកអរក្នុងធម៌មានសភាពយ៉ាងនេះ ទើបបានឈ្មោះថាជាធំដ៏ប្រសើរដោយវិសេស ជាងសេចក្ដីត្រេកអរទាំងឡាយទាំងពួងដោយពិត ព្រោះហេតុដូច្នោះ បានជាសម្ដេចព្រះវិសុទ្ធិទេពសម្ពុទ្ធជាម្ចាស់ ទ្រង់សម្ដែងថា សព្វរតឹធម្មរតីជិនាតិ ប្រែថា សេចក្ដីត្រេកអរក្នុងធម៌ អាចឈ្នះនូវសេចក្ដី

ត្រេកអរទាំងពួងដោយពិតក្នុងលោក គ្មានសេចក្តីត្រេកអរអ្វីប្រៀបផ្ទឹមបាន ។

ប្រស្នាទីបួន អធិប្បាយថា ព្រះអរហត្តផលដែលបង្កើតឡើងក្នុងទីបំផុតនៃកិរិយាអស់ទៅនៃតណ្ហាដោយពុំមានសល់ បានឈ្មោះថាអស់ទៅនៃតណ្ហា ព្រះអរហត្តផលនោះជាធំប្រសើរដោយវិសេស ជាងធម៌ទាំងពួង ព្រោះភាវៈនៃព្រះអរហត្តផលនោះអាចគ្របសង្កត់នូវកងទុក្ខក្នុងវដ្តទាំងអស់បានដោយពិត ព្រោះហេតុដូច្នោះបានជាសម្តេចព្រះសព្វញ្ញូបរមគ្រូជាម្ចាស់ទ្រង់សម្តែងថា តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ប្រែថាកិរិយាអស់ទៅនៃតណ្ហា អាចឈ្នះនូវកងទុក្ខទាំងពួងក្នុងលោកដោយពិត ។

នាកាលព្រះសាស្តាជាម្ចាស់ កាលទ្រង់សម្តែងនូវសេចក្តីអធិប្បាយនៃប្រស្នានោះ ដោយគាថានេះយ៉ាងនេះចប់ហើយ កិរិយាត្រាស់ដឹងនូវធម្មរសប្រាំមានចក្ខុធម្មរសជាដើម មានប្រាកដដល់សត្វទាំងឡាយ ប្រាំបីមឺនបួនពាន់ អាចផឹកទឹកអម្រិតរសគឺអមតមហានិព្វាន ដែលជាធម៌នាំមកនូវសេចក្តីសុខដោយបំណែកមួយ ។

សម្ដេចព្រះបមត្រៃទិព្យអម្រិន្ទ្រាធិរាជ  បានស្ដាប់នូវធម្មកថានៃព្រះសាស្ដាទ្រង់សម្ដែងដូច្នេះហើយ  ក៏លើកឡើងនូវក្រពុំអញ្ជលីប្រណម្យហើយទូលថាដូច្នេះ ។

ភន្តេឯវំជេដ្ឋកេនាមធម្មទានេ  កិមត្ថំអម្ហាកំបត្តិំទាបេថ

ឥតោបដ្ឋាយសោភិក្ខុសំឃស្ស កថេត្វាបត្តិំទាបេថភន្តេ ។

ប្រែថា  បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន  នាកាលធម្មទានឈ្មោះថាធំប្រសើរដោយវិសេសដូច្នេះហើយ  ព្រះអង្គពុំបានញុំាងបរិសទ្យទាំងឡាយមានភិក្ខុបរិសទ្យជាដើម  បំពោះនូវចំណែកបុណ្យដល់យើងទាំងឡាយផងព្រោះហេតុអ្វី  បពិត្រព្រះអង្គដ៏ចំរើន  សូមព្រះអង្គទ្រង់សង្គ្រោះ  ញុំាងភិក្ខុសំឃដែលបានសម្ដែងនូវធម៌ទ្យ ៗ បំពោះនូវចំណែកបុណ្យ  ដល់យើងទាំងឡាយ  ចាប់ដើមតាំងតែអំពីថ្ងៃនេះទៅ ។

សម្ដេចព្រះបរមគ្រូសាស្ដាជាម្ចាស់  ព្រះអង្គបានស្ដាប់ពាក្យព្រះឥន្ទ្រកោសិយរាជទូលដូច្នោះហើយ  ព្រះអង្គទ្រង់ប្រជុំនូវភិក្ខុសំឃទាំងពួងចូលមកជួបជុំហើយ  មានព្រះពុទ្ធដីកាថាភិក្ខវេ  ម្នាលភិក្ខុទាំងឡាយ  អ្នកទាំងឡាយត្រូវធ្វើតាំងពីក្នុង

ថ្ងៃនេះជាដើមទៅ បើបានសម្តែងឬស្តាប់ធម៌យ៉ាងធំក្តី បានសម្តែងឬស្តាប់ធម៌ប្រក្រតីក្តី បានចូលទៅប្រជុំគ្នានិយាយធម៌ក្តី ដ៏ហោចទៅសូម្បីសម្តែងនូវអនុមោទនាក្តី គប្បីឲ្យនូវបំណែកបុណ្យដល់សត្វទាំងឡាយទាំងពួង សព្វ ៗ កាលតរៀងទៅ ៕

ព្រោះហេតុដូច្នោះ អ្នកប្រាជ្ញទាំងឡាយជាន់ក្រោយ លោកអាងសេចក្តីអនុញ្ញាតនេះ លោកតែងធម៌អាកាសង្ហា យាទេវតា ឥអិតា សំរាប់ត្រូវឧទ្ទិសបំណែកបុណ្យជូនទៅសត្វទាំងឡាយទាំងពួង មានទេវតាជាដើមដោយពិត ។០៚—

សម្តែងរឿងសក្កបញ្ហា ប្រស្នាដែលព្រះឥន្ទ្រាធិរាជសួរព្រះសម្មាសម្ពុទ្ធ ចប់សេចក្តីដោសង្ខេបតែប៉ុណ្ណោះ ហោង ។